**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៧១)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១ ១៧៨នាក់ នៃរោងចក្រ សហគ្រាសទាំង១៦ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង១៦ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ អង្គារ ៦កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ១៦ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 3 |
| 1 | ក្រុមហ៊ុន ជូនលី អ៊ិនធើណេសិនណាល ឯ ក | តាកែវ |
| 2 | ក្រុមហ៊ុន ហ្វ្រេសហ្វូល(ខេបូឌា)ថេកស្ទាយ ខូ.អិលធីឌី | តាកែវ |
| 3 | ក្រុមហ៊ុន កៅរ៉េ ស្ព័ត អិលធីឌី | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 13 |
| 4 | ក្រុមហ៊ុន អ៊ិនស្ប៉ាយឌ៍ ដាយនីង | ភ្នំពេញ |
| 5 | ក្រុមហ៊ុន បារអាតហ្គត ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 7 | ក្រុមហ៊ុន អលឌ្រីម (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ស្តារី អ៊ីម៉ិច ខូ អិលធីឌី (សណ្ឋាគារស្តារីអង្គរ) | សៀមរាប |
| 10 | ក្រុមហ៊ុន អឹបៅអេស៊ា | សៀមរាប |
| 11 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 12 | អាហារដ្ឋានផ្ទះបាយខ្មែរភៀក | សៀមរាប |
| 13 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 14 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 15 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 16 | ក្រុមហ៊ុន ថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |